**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាល

## និងការប្តូរស្រុកស្វាយរៀង ទៅជាក្រុងស្វាយរៀង នៃខេត្តស្វាយរៀង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកស្វាយរៀង ស្រុកស្វាយទាប ស្រុកកំពង់រោទិ៍ និង ស្រុកស្វាយជ្រំ នៃខេត្តស្វាយរៀង ដោយកាត់យកឃុំចំនួនបី គឺ ឃុំសង្ឃ័រ ពីស្រុកស្វាយទាប ឃុំស្វាយតឿពីស្រុក កំពង់រោទិ៍ និងឃុំចេក ពីស្រុកស្វាយជ្រំ បញ្ចូលទៅក្នុងស្រុកស្វាយរៀង នៃខេត្តស្វាយរៀង។

មាត្រា ២.-

ត្រូវបានប្តូរស្រុកស្វាយរៀង ទៅជា ក្រុងស្វាយរៀង នៃខេត្តស្វាយរៀង ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងស្វាយរៀង ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យ នេះ ។

មាត្រា ៣.-

ត្រូវបានប្តូរឃុំទាំងប្រាំពីរនៃ ក្រុងស្វាយរៀង ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំស្វាយរៀង | ទៅជា | សង្កាត់ស្វាយរៀង |
| ២- ឃុំព្រៃឆ្លាក់ | ទៅជា | សង្កាត់ព្រៃឆ្លាក់ |
| ៣- ឃុំគយត្របែក | ទៅជា | សង្កាត់គយត្របែក |
| ៤- ឃុំពោធិ៍តាហោ | ទៅជា | សង្កាត់ពោធិ៍តាហោ |
| ៥- ឃុំសង្ឃ័រ | ទៅជា | សង្កាត់សង្ឃ័រ |
| ៦- ឃុំស្វាយតឿ | ទៅជា | សង្កាត់ស្វាយតឿ |
| ៧- ឃុំចេក | ទៅជា | សង្កាត់ចេក |

មាត្រា ៤.-

ត្រូវផ្ទេរទីតាំងសាលាស្រុកស្វាយរៀង ដែលស្ថិតនៅក្នុងសង្កាត់ស្វាយរៀង ទៅជា សាលា ក្រុង ស្វាយរៀង ។

មាត្រា ៥.-

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងស្វាយរៀង ត្រូវអនុលោមទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តស្វាយរៀង អភិបាលក្រុងស្វាយរៀង អភិបាលស្រុកស្វាយទាប អភិបាលស្រុកកំពង់រោទិ៍ អភិបាលស្រុកស្វាយជ្រំ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

